# លក្ខខន្តិកៈ

## ការធានារ៉ាប់រងលើការសម្រាកព្យាបាលនៅមន្ទីរពេទ្យប៊ីម៉ាហែល

### <u>នរណានឹងទទួលបានការធានា?</u>

ការសម្រាកព្យាបាលនៅមន្ទីរពេទ្យប៊ីម៉ាហែល គឺត្រូវតែមានឈ្មោះនៅក្នុងគោលការណ៍ ដើម្បីទទួលបានការធានា ។

### <u>អាយុ:</u>

អ្នកត្រូវតែមានអាយុចន្លោះពី 18-69ឆ្នាំ(ទាំងពីរត្រូវបានរាប់បញ្ចូល)។

### <u>ការកាត់ទឹកប្រាក់ នឹងការធានា:</u>

- ការកាត់ទឹកប្រាក់បុព្វលាភ នឹងទទួលបានការធានារ៉ាប់រង 100% ដោយឥតគិតថ្លៃនៅក្នុងថ្ងៃបន្ទាប់ពីការចុះឈ្មោះ ហើយការធានារ៉ាប់រងនេះគឺទទួលបានបន្ទាប់ពីមានការកាត់ទឹកប្រាក់បានជោគជ័យ។ ឧទាហរណ៍៖ ប្រសិនបើលក្ខិណាបានធ្វើការចុះឈ្មោះនៅថ្ងៃទី15 ខែមករា ហើយទឹកប្រាក់បុព្វលាភរបស់នាងគឺត្រូវបានបង់ នឹងទទួលបានការធានារ៉ាប់រង 100%លើគ្រោះថ្នាក់ចៃដន្យនៅក្នុងថ្ងៃទី16 ខែមករា ហើយនាងក៏ទទួលបានការធានារ៉ាប់រងនៅក្នុងថ្ងៃទី1 ខែកុម្ភៈ គឺអាស្រ័យលើចំនួនទឹកប្រាក់ដែលបានកាត់នៅខែមុន(ទាំងគ្រោះថ្នាក់ចៃដន្យ នឹងជំងឺ)។
- ការទាមទារសំណងត្រូវបានទុករយៈពេលរហូតដល់ 12 ខែនៃការចូលសម្រាកព្យាបាលនៅមន្ទីពេទ្យ។

### <u>របៀបក្នុងការទាមទារសំណង:</u>

- ដំណើរការនៃការទាមទារសំណង គឺធ្វើឡើងបន្ទាប់ពីឯកសារខាងក្រោមត្រូវបានដាក់ជូន៖
  A. ភស្តុតាងនៃការចុះឈ្មោះ (សារបញ្ជាក់ពីការចុះឈ្មោះ ឬការធានារ៉ាប់រង) ។
  B. ឯកសារបញ្ជាក់ពីអត្តសញ្ញាណ (អត្តសញ្ញាណប័ណ្ណ, សៀវភៅគ្រួសារ, ប័ណ្ណបើកបរ ឬលិខិតឆ្លងដែន) ។
  C. ព័ត៌មានលំអិតពីថ្ងៃចូល និងថ្ងៃចេញពីមន្ទីរពេទ្យ, ឈ្មោះអ្នកជំងឺ, អាយុ និងភេទ, ថ្ងៃនៃការជូនដំណឹង,ការអង្កេតដែរបានធ្វើរួច, ការព្យាបាលដែលបានផ្តល់ជូន មានត្រា នឹងហត្ថលេខាពីវេជ្ជបណ្ឌិត ឬវិក័យប័ត្រទូទាត់ និងវិក័យប័ត្រចុងក្រោយ) ។

## ករណីលើកលែងមិនផ្តល់សំណង:

១) សង្គ្រាម ការឈ្លានពាន សកម្មភាពរបស់សត្រូវបរទេស ការប្រទូសរ៉ាយផ្សេងៗ (ទោះជាបានប្រកាស ឬ មិនបានប្រកាសសង្គ្រាមក្តី) សង្គ្រាមស៊ីវិល ឧទ្ទាមកម្មឬបដិវត្តន៍ ការប្រើអំណាចយោធា ឬដណ្តើម អំណាច កូដកម្ម កុប្បកម្ម ការកោលាហលស៊ីវិល ភេរវកម្ម ឬផលវិបាកផ្សេងទៀត ដែលកើតឡើង ដោយសារសកម្មភាពទាំងនោះ។

២) ហានិភ័យ ឬការបាត់បង់ ដោយសារអាវុធនុយក្លេអ៊ែរ យុទ្ធភ័ណ្ឌជីវៈសាស្ត្រ និងគីមីផ្សេងៗ។

៣) លក្ខខណ្ឌសុខភាពមុនចុះឈ្មោះ ឬកើតឡើងវិញក្នុងអំឡុងពេល៣ខែដំបូងបន្ទាប់ពីចុះឈ្មោះ។

៤) ការធ្វើអត្តឃាត – ២ឆ្នាំដំបូងក្នុងរយៈពេល នៃការចុះឈ្មោះលើគោលការណ៍ធានារ៉ាប់រង។

៥) មានផ្ទៃពោះឬសម្រាលកូនក្នុងរយៈពេល ៩ខែ បន្ទាប់ពីការចុះឈ្មោះលើគោលការណ៍ធានារ៉ាប់រង។

៦) ការវះកាត់កែសម្ផស្ស។

៧) ការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀនខុសច្បាប់។

## ការកាត់ផ្តាច់សេវាកម្ម:

គោលការណ៍នេះអាចត្រូវបានលុបចោលដោយទូរស័ព្ទទៅប៊ីម៉ាលេខ 010 242 248។ ការកាត់បុព្វលាភនឹងត្រូវបញ្ឈប់ក្នុងរយៈពេល 48ម៉ោង។ ប្រសិនបើម្ចាស់ប័ណ្ណសន្យាធានារ៉ាប់រង ជ្រើសយកការបង្វិលថ្លៃប្រាក់បុព្វលាភជូនវិញ ប៊ីម៉ា ត្រូវបង្វិលប្រាក់បុព្វលាភជូនវិញចំនួន90% នៃប្រាក់បុព្វលាភក្នុងរយៈពេលដែលបានបង់រួចដោយការធានាមិនទាន់ត្រូវបានផ្តល់ជូននៅឡើយ បើមិនទាន់បានរៀបចំឯកសារទាមទារសំណងទេនោះ។ ប្រសិនបើវាត្រូវបានរៀបចំឯកសារទាមទារសំណងរួចហើយ នោះមិនមានការបង្វិលប្រាក់សងត្រឡប់វិញទេ នៅពេលមានការលុបប័ណ្ណសន្យាធានារ៉ាប់រងចោល។